Australian Government
Department of Social Services



# ការកាត់ស្បែកចុងប្រដាប់បន្តពូជស្ត្រី

## ( Female Genital Mutilation/Cutting )

### តើការកាត់ស្បែកចុងប្រដាប់បន្តពូជស្ត្រីគឺជាអ្វី?

ការកាត់ស្បែកចុងប្រដាប់បន្តពូជស្ត្រី គឺជាការកាត់ ឬកែដោយចេតនានៃតំបន់ប្រដាប់បន្តពូជស្ត្រីដោយគ្មានមូលហេតុវេជ្ជសាស្ត្រ។ វាមានឈ្មោះជាច្រើនដូចជាការកាត់ ការកាត់ស្បែកចុងប្រដាប់បន្តពូជស្ត្រី ការកាត់ស្បែកចុងប្រដាប់បន្តពូជស្ត្រីតាមវិធីសាសនា។ វាមានគ្រោះថ្នាក់ដល់សុខភាពរបស់ស្ត្រី និងមិនចាំបាច់ទាល់តែសោះ។

> ប្រសិនបើអ្នក ឬជនណាម្នាក់ដែលអ្នកស្គាល់ ស្ថិតនៅក្នុងសភាពគ្រោះថ្នាក់ សូមទូរស័ព្ទទៅប៉ូលីសលេខ **000**។
>
> ប៉ូលីសនៅប្រទេសអូស្ត្រាលីមានសុវត្ថិភាព ហើយអាចទុកចិត្តបាន។
>
> សម្រាប់ការប្រឹក្សាយោបល់ និងការផ្តល់ព័ត៌មានជាសម្ងាត់ ហើយឥតគិតថ្លៃ សូមទូរស័ព្ទទៅ 1800RESPECT លេខ **1800 737 732**។
>
> ប្រសិនបើអ្នកត្រូវការអ្នកបកប្រែភាសាដោយឥតគិតថ្លៃ សូមទូរស័ព្ទទៅលេខ **131 450**។

### អ្នកអាចរកជំនួយ និងការគាំទ្រខាងវេជ្ជសាស្ត្របាននៅក្នុងប្រទេសអូស្ត្រាលី។

ប្រសិនបើអ្នកទទួលរងនូវអំពើណាមួយក្នុងចំណោមអំពើទាំងនេះ អ្នកអាចទទួលបានការថែទាំ និងការគាំទ្រខាងសុខភាពដោយឥតគិតថ្លៃនៅក្នុងប្រទេសអូស្ត្រាលី។ វេជ្ជបណ្ឌិត គិលានុបដ្ឋាក អ្នកជំនាញផ្នែកវេជ្ជសាស្ត្រផ្សេងទៀត និងគ្រូបង្រៀនអាចជួយអ្នកបាន។

ប្រសិនបើអ្នកមានគម្រោងក្នុងការមានកូន អ្នកអាចពិគ្រោះជាមួយវេជ្ជបណ្ឌិត គិលានុបដ្ឋាក អ្នកជំនាញផ្នែកវេជ្ជសាស្ត្រផ្សេងទៀត ដើម្បីទទួលបានការគាំទ្របន្ថែមនៅពេលអ្នកមានផ្ទៃពោះ និងនៅពេលអ្នកមានកូន។

### ការកាត់ស្បែកចុងប្រដាប់បន្តពូជស្ត្រី គឺជាបទឧក្រិដ្ឋធ្ងន់ធ្ងរនៅក្នុងប្រទេសអូស្ត្រាលី។

ការកាត់ស្បែកចុងប្រដាប់បន្តពូជស្ត្រី គឺជាអំពើខុសច្បាប់នៅក្នុងប្រទេសអូស្ត្រាលី។ នេះរាប់បញ្ចូលទាំងការបញ្ជូនមនុស្សម្នាក់ទៅក្រៅប្រទេសដើម្បីអនុវត្តអំពើនេះ ឬជួយសម្របសម្រួល គាំទ្រ ឬលើកទឹកចិត្តនរណាម្នាក់ឱ្យអំពើធ្វើបែបដូចនេះ។

ជនណាដែលប្រព្រឹត្តបទឧក្រិដ្ឋទាំងនេះ អាចជាប់ពន្ធនាគារ ទោះបីអ្នកនោះជាបុរស ឬស្ត្រីក៏ដោយ។

ប្រសិនបើអ្នកទទួលរងនូវអំពើណាមួយក្នុងចំណោមទាំងនេះ អ្នកត្រូវបានលើកទឹកចិត្តឱ្យស្វែងរកជំនួយ ហើយនឹងមិនមានទោសនៅក្រោមច្បាប់អូស្ត្រាលីទេ។

### មានសេវាផ្សេងៗទៀត និងធនធានដែលអាចជួយបាន។

អ្នកអាចស្វែងរកព័ត៌មាន ស្តីពីការកាត់ប្រដាប់បន្តពូជស្ត្រីនៅតាមវិបសាយ **កញ្ចប់ឧបករណ៍អប់រំជាតិសម្រាប់ការយល់ដឹងពីការកាត់ស្បែកចុងប្រដាប់បន្តពូជស្ត្រី (National Education Toolkit for Female Genital Mutilation/Cutting Awareness)** នៅត្រង់ **www.netfa.com.au**។

**1800RESPECT** គឺជាសេវាផ្តល់ការប្រឹក្សាអំពីការរំលោភបំពានខាងផ្លូវភេទ អំពើហិង្សាតាមផ្ទះ និងក្នុងគ្រួសារទូទាំងប្រទេសរបស់ប្រទេសអូស្ត្រាលី។ សេវានេះផ្តល់ព័ត៌មាន និងការប្រឹក្សាតាមទូរស័ព្ទ និងអ៊ីនធើណិតដោយឥតគិតថ្លៃ ហើយដោយសម្ងាត់។ អ្នកផ្តល់ការប្រឹក្សានឹងស្តាប់អ្នក ឆ្លើយសំណួរ និងអាចបញ្ជូនអ្នកទៅកាន់សេវាជំនួយផ្សេងៗទៀតនៅតាមតំបន់ដែលអ្នករស់នៅ។

ចូរទូរស័ព្ទទៅលេខ **1800 737 732** ឬបើកចូលវិបសាយរបស់ **1800RESPECT** នៅត្រង់ **www.1800RESPECT.org.au**។

ប្រសិនបើអ្នក ឬនរណាម្នាក់ដែលអ្នកស្គាល់ ត្រូវបានគេនាំយកទៅប្រទេសក្រៅដើម្បីអនុវត្តអំពើដូចនេះ ឬអ្នកគិតថាពួកគេកំពុងស្ថិតក្នុងភាពប្រឈមនឹងការនាំចេញពីប្រទេសសម្រាប់អនុវត្តអំពើនេះ សូមទូរស័ព្ទទៅមជ្ឈមណ្ឌលកុងស៊ុល (Consular Emergency Centre) ធ្វើការ២៤ម៉ោង ៧ថ្ងៃក្នុង១សប្តាហ៍ លេខ 1300 555 135 (ពីប្រទេសអូស្ត្រាលី) ឬ **+61 2 6261 3304** (ពីក្រៅប្រទេស) ឬទាក់ទងបេសកកម្មអូស្ត្រាលីក្រៅប្រទេសដែលនៅជិតបំផុត តាមវិបសាយ **dfat.gov.au**។

## តើអ្នកត្រូវការអ្នកបកប្រែភាសាឬទេ?

សូមទូរស័ព្ទទៅ **Translating and Interpreting Service** (TIS) ដោយឥតគិតថ្លៃ លេខ **131 450**។ TIS អាចជួយអ្នកឱ្យប្រាស្រ័យទាក់ទងជាមួយសេវាផ្សេងៗទៀតបាន ក៏ប៉ុន្តែ TIS មិនផ្តល់ការប្រឹក្សាទេ។ គ្រប់ការហៅទូរស័ព្ទទាំងអស់គឺឥតគិតថ្លៃ និងសម្ងាត់។